# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៩. សរណន

# សារាចរណែនាំ

## សម្រាប់អនុវត្តជាអចិន្ត្រៃយ៍ ស្តីពីការរៀបចំចាត់តាំងព្រះរាជពិធីបុណ្យទានសមាស បុណ្យប្រពៃណីជាតិ ប្រពៃណីសាសនា បុណ្យជាតិ-បុណ្យអន្តរជាតិ

ព្រះរាជាណាចក្រកម្ពុជា មានពិធីបុណ្យជាច្រើនប្រចាំឆ្នាំ ដូចជាព្រះរាជពិធីបុណ្យទានសមាស បុណ្យប្រពៃណីជាតិ ប្រពៃណីសាសនា បុណ្យជាតិនិងបុណ្យអន្តរជាតិ ។ បុណ្យទាំងនោះ ត្រូវប្រព្រឹត្តទៅជាទៀងទាត់តាមប្រតិទិនចន្ទគតិខ្លះ និងតាមសុរិយគតិខ្លះ។ ព្រះមហាក្សត្រ រាជរដ្ឋាភិបាល និងប្រជាពលរដ្ឋខ្មែរ តែងប្រារព្ធពិធីបុណ្យទាំងនោះ ជារៀងរាល់ឆ្នាំ ដោយរក្សាបាននូវខ្លឹមសារ និងរូបភាពចាត់តាំង ទៅតាមអត្ថន័យនៃបុណ្យនិមួយៗ ។

កន្លងមក ដើម្បីថែរក្សាការពារនូវប្រពៃណី ទំនៀមទម្លាប់ ជំនឿសាសនា វប្បធម៌ អរិយធម៌ ដែលជាអត្តសញ្ញាណដ៏ថ្លៃថ្នូររបស់ជាតិឱ្យបានគង់វង្ស រាជរដ្ឋាភិបាល តែងដាក់ចេញនូវសារាចរណែនាំ ដោយឡែកៗ ទៅតាមផ្នែកជំនាញនៃបុណ្យនិមួយៗ សម្រាប់រៀបចំចាត់តាំងអនុវត្ត នៃពិធីបុណ្យទាំងនោះ ទទួលបានលទ្ធផលល្អប្រសើរ ។

ក្នុងស្មារតីកែទម្រង់អត្តបទបទដ្ឋាននៃការរៀបចំពិធីបុណ្យទាំងនោះ ឱ្យកាន់តែប្រសើរឡើង រាជរដ្ឋាភិបាល ដាក់ចេញនូវសារាចរណែនាំរួមមួយ សម្រាប់អនុវត្តជាអចិន្ត្រៃយ៍ តាមកាលបរិច្ឆេទ និងខ្លឹមសារដូចខាងក្រោមនេះ :

## I. កាលបរិច្ឆេទ :

**ក/. ព្រះរាជពិធីបុណ្យទានសមាស បុណ្យប្រពៃណីជាតិ ប្រពៃណីសាសនា :**

- បុណ្យមាឃបូជា : ថ្ងៃ ១៥ កើត ខែ មាឃ
- បុណ្យវិសាខបូជា : ថ្ងៃ ១៥ កើត ខែ ពិសាខ
- បុណ្យច្រត់ព្រះនង្គ័ល : ថ្ងៃ ១-២-៣ និងថ្ងៃ ៤ រោច ខែ ពិសាខ
- បុណ្យកាន់បិណ្ឌ ភ្ជុំបិណ្ឌ : ថ្ងៃ ១៤-១៥ រោច ខែ ភទ្របទ និង ១ កើត ខែ អស្សុជ
- បុណ្យកឋិនទាន : ពីថ្ងៃ ១ រោច ខែ អស្សុជ ដល់ ១៥ កើត ខែ កត្តិក
- បុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក : ថ្ងៃ ១៤-១៥ កើត និង ថ្ងៃ ១ រោច ខែ កត្តិក
- បុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ : ថ្ងៃទី ១៤-១៥-១៦ ខែ មេសា

**ខ/. ព្រះរាជពិធីបុណ្យចំរើនព្រះជន្មព្រះមហាក្សត្រ :**

- បុណ្យចំរើនព្រះជន្មសម្តេចព្រះរាជអគ្គមហេសី **នរោត្តម មុនិនាថ សីហនុ** : ថ្ងៃទី ១៨ ខែ មិថុនា
- បុណ្យចំរើនព្រះជន្មព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** : ថ្ងៃទី ៣០-៣១ ខែ តុលា និង ថ្ងៃទី ០១ ខែ វិច្ឆិកា

គ/. **បុណ្យជាតិ** :

. បុណ្យប្រកាសរដ្ឋធម្មនុញ្ញ និង ព្រះរាជពិធីគ្រងរាជសម្បត្តិជាថ្មី របស់ព្រះមហាក្សត្រ : ថ្ងៃទី ២៤ ខែ កញ្ញា

. បុណ្យឯករាជជាតិ : ថ្ងៃទី ០៩ ខែ វិច្ឆិកា

ឃ/. **ទិវាបុណ្យជាតិ** :

. បុណ្យជ័យជំនះលើរបបប្រល័យពូជសាសន៍ : ថ្ងៃទី ០៧ ខែ មករា

. ទិវាកំចាត់មីន : ថ្ងៃទី ២៤ ខែ កុម្ភៈ

. ទិវានយោបាយទឹក : ថ្ងៃទី ០៤ ខែ មីនា

. ទិវាកំចាត់រោគរបេង : ថ្ងៃទី ២៤ ខែ មីនា

. ទិវាវប្បធម៌ : ថ្ងៃទី ០៣ ខែ មេសា

. ទិវាសេរីភាពខាងពត៌មាន : ថ្ងៃទី ០៣ ខែ ឧសភា

. រុក្ខទិវា : ថ្ងៃទី ០៩ ខែ កក្កដា

. ទិវាទេសចរណ៍ : ថ្ងៃទី ២៧ ខែ កញ្ញា

. ទិវាមនុស្សចាស់ : ថ្ងៃទី ០១ ខែ តុលា

. ទិវាគ្រូបង្រៀន : ថ្ងៃទី ០៥ ខែ តុលា

. ទិវាសន្ធិសញ្ញាសន្តិភាពកម្ពុជានៅប៉ារីស : ថ្ងៃទី ២៣ ខែ តុលា

ង/. **ទិវាបុណ្យអន្តរជាតិ** :

. បុណ្យចូលឆ្នាំសកល : ថ្ងៃទី ០១ ខែ មករា

. ទិវានារីអន្តរជាតិ : ថ្ងៃទី ០៨ ខែ មីនា

. ទិវាពិភពលោកទឹកនិងឧតុនិយម : ថ្ងៃទី ២២ ខែ មីនា

. ទិវាសុខភាពពិភពលោក : ថ្ងៃទី ០៧ ខែ មេសា

. ទិវាពលកម្មអន្តរជាតិ : ថ្ងៃទី ០១ ខែ ឧសភា

. ទិវាកាកបាទក្រហមកម្ពុជា : ថ្ងៃទី ០៨ ខែ ឧសភា

. ទិវាកុមារអន្តរជាតិ : ថ្ងៃទី ០១ ខែ មិថុនា

. ទិវាបរិស្ថានអន្តរជាតិ : ថ្ងៃទី ០៥ ខែ មិថុនា

. ទិវាប្រឆាំងគ្រឿងញៀន : ថ្ងៃទី ២៦ ខែ មិថុនា

. ទិវាអនក្ខរកម្មអន្តរជាតិ : ថ្ងៃទី ០៨ ខែ កញ្ញា

. ទិវាសន្តិភាពអន្តរជាតិ : ថ្ងៃទី ២១ ខែ កញ្ញា

. ទិវាអនាម័យបរិស្ថាន : ថ្ងៃទី ២៣ ខែ វិច្ឆិកា

. ទិវាប្រឆាំងជម្ងឺអេដស៍ : ថ្ងៃទី ០១ ខែ ធ្នូ

. ទិវាសិទ្ធិមនុស្ស : ថ្ងៃទី ១០ ខែ ធ្នូ

II. **ភារកិច្ចត្រូវអនុវត្ត** :

- ប្រគល់ភារកិច្ច ជូនក្រសួងព្រះបរមរាជវាំង ចាត់តាំងព្រះរាជពិធីបុណ្យទាំងសមាសប្រចាំឆ្នាំ នៅក្នុងព្រះបរមរាជវាំង ឱ្យស្របតាមប្រពៃណីជាតិ ប្រពៃណីសាសនា និងតាមការសព្វព្រះរាជហឫទ័យ របស់**ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង និង សម្តេចព្រះរាជអគ្គមហេសី** ជាទីសក្ការៈ .

- ប្រគល់ភារកិច្ចជូន គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ សហការជាមួយក្រសួងព្រះបរមរាជវាំង និងក្រសួងពាក់ព័ន្ធ ចាត់តាំងព្រះរាជពិធីបុណ្យទ្វាទសមាស បុណ្យជាតិ បុណ្យប្រពៃណីជាតិ បុណ្យប្រពៃណីសាសនា ឱ្យធានាបានរូបភាពចាត់តាំងនិងខ្លឹមសារ ស្របតាមគោលបំណង សំណូមពរ និងប្រធានបទ នៃបុណ្យ និមួយៗ ដោយត្រូវមានផែនការណែនាំលំអិត សម្រាប់អនុវត្តជាក់ស្តែង ។

- ប្រគល់ភារកិច្ចជូនក្រសួង និងអង្គភាពសាមី ដែលជាសមាជិកគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ដែលមានពាក់ព័ន្ធនឹងទិវាបុណ្យជាតិ-អន្តរជាតិ តាមផ្នែកជំនាញនិមួយៗ សហការជាមួយគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ រៀបចំផែនការណែនាំលំអិត ស្តីពីអត្ថន័យខ្លឹមសារ រូបភាពចាត់តាំង គោលបំណង សំណូមពរ និងប្រធានបទ សម្រាប់ចាត់តាំងអនុវត្តឱ្យបានស្របទៅតាមសភាពការណ៍ប្រទេសជាតិ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល តាមដំណាក់កាលនិមួយៗ ។

- ក្រសួងជំនាញនិមួយៗ ដែលពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងឬអង្គភាពសាមី បង្កលក្ខណៈងាយស្រួលតាមសមត្ថកិច្ច បំរើឱ្យការរៀបចំពិធីបុណ្យនិមួយៗ តាមសំណូមពរនិងតម្រូវការចាំបាច់នៃការចាត់តាំងរៀបចំ ឱ្យទទួលបានលទ្ធផលល្អ ។

- ប្រគល់ភារកិច្ចជូនគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ធ្វើការណែនាំប្រជុំកំណត់បែងចែកភារកិច្ច ទៅគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័ន ឱ្យចាត់តាំងរៀបចំពិធីបុណ្យតាមប្រតិទិនកំណត់ ដោយផ្អែកលើខ្លឹមសារនិងរូបភាពចាត់តាំង ជាក់ស្តែង ។

## III. មូលដ្ឋាន សម្ភារៈ ថវិកា :

- ពាក់ព័ន្ធនឹងសម្ភារៈ ថវិកា ដែលត្រូវប្រើប្រាស់ និងចំណាយបំរើការរៀបចំពិធីបុណ្យនិមួយៗ ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័នសាមី ត្រូវប្រើប្រាស់ឱ្យអស់លទ្ធភាពនូវថវិកាដែលមានក្នុងគម្រោងប្រចាំឆ្នាំរបស់ខ្លួន ដោយត្រូវផ្តែប្រឹតនិងសន្សំសំចៃកម្រិតខ្ពស់ តែត្រូវធានាការរៀបចំឱ្យបានទទួលលទ្ធផលល្អប្រសើរ ។

- ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវត្រៀមលក្ខណៈរៀបចំដោះស្រាយសម្ភារៈ ថវិកា និងត្រួតពិនិត្យម៉ត់ចត់នូវគម្រោងចំណាយបំរើការរៀបចំបុណ្យនិមួយៗ ដែលសាមីអង្គភាព បានលើកឡើង ។

ក្នុងករណី មានការចាត់តាំងរៀបចំបុណ្យជាលក្ខណៈពិសេស រាជរដ្ឋាភិបាល នឹងដាក់ចេញនូវសារាចរណែនាំមួយ ដោយឡែកសម្រាប់អនុវត្តជាក់ស្តែង ។

ក្រោយការប្រារព្ធពិធីបុណ្យនិមួយៗចប់សព្វគ្រប់ , សាមីក្រសួង ស្ថាប័ន ត្រូវធ្វើរបាយការណ៍ជូនគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ដើម្បីបូកសរុបរាយការណ៍ ជូនរាជរដ្ឋាភិបាល ។

ទទួលបានសារាចរណែនាំនេះ, រាជរដ្ឋាភិបាល សង្ឃឹមថា សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានស្ថាប័ន និងអភិបាលខេត្ត-ក្រុង នឹងចាត់តាំងអនុវត្តទទួលបានលទ្ធផលល្អប្រសើរ ។/.

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងគ្រប់ខេត្ត-ក្រុង
- អគ្គលេខាធិការដ្ឋាន គ.ម.ជ.អ
- ឯកសារ-កាលប្បវត្តិ